អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សេចក្តីប្រកាសព័ត៌មានរបស់អង្គភាពគាំពារការការពារក្តី

## ការប្រកាន់ខ្ជាប់តាមបទដ្ឋានអន្តរជាតិ: អង្គភាពគាំពារការការពារក្តីតែងតាំងមេធាវីដើម្បីការពារផលប្រយោជន៍របស់ជនសង្ស័យនៅក្នុងសំណុំរឿង ០០៣ និង០០៤

អង្គភាពគាំពារការការពារក្តីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អវតក”) បានតែងតាំងលោកមេធាវី **គង់ សំអុន** ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីការពារផលប្រយោជន៍ទូទៅរបស់ជនសង្ស័យមិនស្គាល់អត្តសញ្ញាណប្រាំ(៥) នាក់ ដែលបច្ចុប្បន្ននេះស្ថិតនៅក្រោមការស៊ើបអង្កេត ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត (“កសចស”) ។ លោកមេធាវី **គង់ សំអុន** បានការពាររឿងក្តីសំខាន់ៗជាច្រើននៅប្រទេសកម្ពុជា ដោយបានការពារអ្នកសារព័ត៌មាន អ្នកនយោបាយ និងបុគ្គលដទៃទៀត ដែលសិទ្ធិមនុស្សជាមូលដ្ឋានរបស់ពួកគេ ត្រូវបានរំលោភបំពាន ។ លោកធ្លាប់បានផ្តល់យោបល់ និងការពារផលប្រយោជន៍របស់សាក្សី ដែលបានបង្ហាញខ្លួននៅចំពោះអង្គជំនុំជម្រះសាលាដំបូងនៅ អវតក ក្នុងសំណុំរឿង ០០១ ផងដែរ ។

ជនសង្ស័យមិនស្គាល់អត្តសញ្ញាណទាំងប្រាំនាក់ក្នុងសំណុំរឿង ០០៣ និង០០៤ នៅ អវតក ប្រឈមនឹងការប៉ះពាល់យ៉ាងច្រើន ពីការស៊ើបអង្កេតដោយគ្មានពេលកំណត់របស់ កសចស ដែលបានប្រមូលភស្តុតាងដាក់បន្ទុកសក្តានុពល ដោយមានការចូលរួមពីសហព្រះរាជអាជ្ញា ប៉ុន្តែ គ្មានការត្រួតពិនិត្យពីមេធាវីការពារក្តី ។ ប្រសិនបើស្ថានការបែបនេះបន្តកាន់តែយូរនោះ ផលប៉ះពាល់ជាសក្តានុពលដល់ជនសង្ស័យនឹងកាន់តែខ្លាំងឡើង ។ ដើម្បីធ្វើឲ្យបានសម្រេចនូវសមភាពនៃការតតាំងក្តីរវាងភាគីទាំងអស់ និងដើម្បីធានាថានីតិវិធីក្នុងសំណុំរឿង ០០៣ និង០០៤ ឆ្លើយតបទៅនឹងបទដ្ឋានអន្តរជាតិនៃការជំនុំជម្រះក្តីដោយយុត្តិធម៌ អង្គភាពគាំពារការការពារក្តីបានតែងតាំងលោកមេធាវី **គង់ សំអុន** ដើម្បីការពារផលប្រយោជន៍ទូទៅរបស់ជនសង្ស័យមិនស្គាល់អត្តសញ្ញាណនៅចំពោះមុខ អវតក ប្រព័ន្ធផ្សព្វផ្សាយ និងសាធារណៈជន ។ លោកមេធាវី **គង់ សំអុន** នឹងឆ្លើយតបចំពោះសំណើសុំផ្តល់យោបល់ពីអ្នកដែលគិតថាខ្លួនអាចប៉ះពាល់ដោយការស៊ើបអង្កេតដែលកំពុងបន្តនេះផងដែរ ។

អនុលោមតាមមាត្រា ២៤ថ្មី នៃច្បាប់ស្តីពីការបង្កើត អវតក និងយោងជាមួយនិយមន័យនៃពាក្យ “ជនសង្ស័យ” នៅក្នុងវិធានផ្ទៃក្នុងនៅ អវតក ជនសង្ស័យមិនស្គាល់អត្តសញ្ញាណដែលស្ថិតនៅក្រោមការ

ស៊ើបអង្កេត មានសិទ្ធិទទួលបានជំនួយពីមេធាវីការពារក្ដីដោយឥតលក្ខខណ្ឌ ។ ការតែងតាំងមេធាវីការពារផលប្រយោជន៍ទូទៅរបស់ជនសង្ស័យ ក៏ត្រូវធ្វើឲ្យស្របតាមច្បាប់អន្តរជាតិ និងអនុវត្តផងដែរ ។

ភ្នំពេញថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០

Rupert Abbott
**មន្ត្រីទទួលបន្ទុក**
**អង្គភាពគាំពារការការពារក្ដី**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Email: abbottr@un.org
Tel: +855(0) 17 500 778

